Animal Welfare.
Worldwide.

ក្រមប្រតិបត្តិអង្គការហ្វ័រផ

FOUR PAWS

Code of Conduct

Animal Welfare.
Worldwide.

OUR VISION	is a world where humans treat animals with respect, empathy, and understanding.	ទស្សនៈវិស័យរបស់យើង	គឺពិភពលោកមួយដែលមនុស្សលោកផ្តល់ការគោរព មេត្តា និងយោគយល់ចំពោះសត្វ។
OUR MISSION	FOUR PAWS is the global animal welfare organisation for animals under direct human influence, which reveals suffering, rescues animals in need and protects them.	បេសកកម្មរបស់យើង	ហ្វ័រផ គឺជាអង្គការសុខុមាលភាពសត្វថ្នាក់សកល សម្រាប់សត្វដែលស្ថិតនៅក្រោមឥទ្ធិពលផ្ទាល់របស់មនុស្សដែលបង្ហាញពីទុក្ខលំបាកជួយ សង្គ្រោះសត្វដែលត្រូវការជំនួយ និងការពារពួកវា។

1 TARGET GROUP

This Code of Conduct applies to all employees, interns, volunteers, contractors and partners of FOUR PAWS Group entities in Cambodia (“**Target Group**”).

For clarity, while the Target Group consists of interns, volunteers, contractors and partners, their relationship with FOUR PAWS is not an employment relationship. Nothing in this Code of Conduct shall be construed to create an employer-employee relationship with interns, volunteers, contractors and partners.

១ ក្រុមគោលដៅ

ក្រមប្រតិបត្តិនេះអនុវត្តចំពោះ និយោជិត កម្មសិក្សាការី អ្នកស្ម័គ្រចិត្ត អ្នកម៉ៅការ និងដៃគូទាំងអស់នៃស្ថាប័នទាំងឡាយក្រោម ហ្វ័រផគ្រុប នៅក្នុងប្រទេសកម្ពុជា(“**ក្រុមគោលដៅ**”)។

ដើម្បីភាពច្បាស់លាស់ ថ្វីដ្បិតតែក្រុមគោលដៅរួមមាន កម្មសិក្សាការី អ្នកស្ម័គ្រចិត្ត អ្នកម៉ៅការ និងដៃគូទំនាក់ទំនងរបស់ពួកគេ ជាមួយ ហ្វ័រផ មិនមែនជាទំនាក់ទំនងការងារឡើយ។ ពុំមានបទប្បញ្ញត្តិណាមួយក្នុងក្រមប្រតិបត្តិនេះត្រូវបានបកស្រាយដើម្បីបង្កើតឲ្យមានទំនាក់ទំនងរវាងនិយោជក និងនិយោជិតរវាង ហ្វ័រផ ជាមួយកម្មសិក្សាការី អ្នកស្ម័គ្រចិត្ត អ្នកម៉ៅការ និងដៃគូឡើយ។

2 INTRODUCTION

The FOUR PAWS vision is a world where humans treat animals with respect, empathy, and understanding.

In order to attain our vision through consistently realising our mission to reveal suffering, rescue animals in need and protect them, we have drawn up the Code of Conduct to serve as a compass to the Target Group of FOUR PAWS.

This Code of Conduct introduces FOUR PAWS principles which must govern all colleagues' decisions and actions. It also demonstrates the commitment of FOUR PAWS to ensuring that the Target Group acts with integrity and deliver the highest standards of quality in everything they do.

Our Code of Conduct is further complemented by individual policies, guidelines and procedures and its principles are drawn in recognition of national and international laws, the Universal Declaration of Human Rights as well as the International Labour Standards, amongst others.

២ សេចក្តីផ្តើម

ចក្ខុវិស័យរបស់ហ្វ័រផ គឺជាពិភពលោកមួយដែលមនុស្សលោកផ្តល់នូវការគោរព មេត្តា និងយោគយល់ចំពោះសត្វ។

ដើម្បីសម្រេចនូវចក្ខុវិស័យរបស់យើង តាមរយៈការសម្រេចបានយ៉ាងខ្ជាប់ខ្ជួននូវបេសកកម្មរបស់យើង ក្នុងការបង្ហាញពីទុក្ខលំបាក ជួយសង្គ្រោះសត្វដែលត្រូវការជំនួយ និងការពារពួកវា យើងបានបង្កើតក្រមប្រតិបត្តិនេះឡើង ដើម្បីបម្រើជាត្រីវិស័យសម្រាប់ក្រុមគោលដៅរបស់ហ្វ័រផ។

ក្រមប្រតិបត្តិនេះណែនាំនូវគោលការណ៍ទាំងឡាយរបស់ហ្វ័រផ ដែលត្រូវតែគ្រប់គ្រងលើការសម្រេចចិត្ត និងសកម្មភាពទាំងអស់របស់មិត្តរួមការងារទាំងឡាយ។ ក្រមនេះក៏បង្ហាញពីការប្តេជ្ញាចិត្តរបស់ ហ្វ័រផ ក្នុងការធានាថា ក្រុមគោលដៅទាំងអស់ធ្វើសកម្មភាពប្រកបដោយសុចរិតភាព និងសម្រេចនូវអ្វីគ្រប់យ៉ាងដែលពួកគេធ្វើជាមួយស្តង់ដារគុណភាពខ្ពស់បំផុត។

ក្រមប្រតិបត្តិរបស់យើងត្រូវបានបំពេញបន្ថែម ដោយគោលនយោបាយ គោលការណ៍ណែនាំ និងនីតិវិធីផ្សេងៗ ហើយគោលការណ៍នៃក្រមនេះត្រូវបានបង្កើតឡើងដោយទទួលស្គាល់ ច្បាប់ជាតិ និងអន្តរជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងស្តង់ដារការងារអន្តរជាតិ ក៏ដូចជាច្បាប់ និងបទបញ្ញត្តិផ្សេងទៀត។

Code of Conduct

ក្រមប្រតិបត្តិ

3 PROMOTING ANIMAL WELFARE

៣ ការលើកកម្ពស់សុខុមាលភាពសត្វ

Animal welfare

សុខុមាលភាពសត្វ

In order to continually work towards FOUR PAWS vision of a world in which humans treat animals with respect, empathy, and understanding:

ដើម្បីបន្តធ្វើការឆ្ពោះទៅសម្រេចចក្ខុវិស័យរបស់ ហ្វ័រផ ក្នុងការបង្កើតពិភពលោកដែលមនុស្សលោកផ្តល់នូវការគោរព មេត្តា និងយោគយល់ ចំពោះសត្វ៖

3.1 I commit to FOUR PAWS mission of revealing inappropriate and life-threatening conditions for animals, developing appropriate solutions, driving them forward in order to implement them in the best possible way, and ensuring that animals in need are rescued and protected.

៣.១ ខ្ញុំសូមប្តេជ្ញាបំពេញបេសកកម្មរបស់ ហ្វ័រផ ក្នុងការបង្ហាញពីស្ថានភាពទាំងឡាយដែលមិនសមរម្យចំពោះ និងគំរាមកំហែងដល់អាយុជីវិតសត្វ បង្កើតដំណោះស្រាយសមស្របដោយជំរុញឱ្យមាននូវការអនុវត្តនូវដំណោះស្រាយតាមមធ្យោបាយល្អបំផុតតាមដែលអាចធ្វើទៅបាន និងធានាថាសត្វទាំងឡាយដែលត្រូវការជំនួយត្រូវបានជួយសង្គ្រោះ និងការពារ។

3.2 I commit to safeguarding the welfare of all animals in FOUR PAWS care, being aware that FOUR PAWS incorporates the One Welfare Framework describing the interconnection between animal welfare, human well-being and their physical and social environment as important elements to consider in the elaboration and implementation of policies and activities related to each of these aspects.

៣.២ ខ្ញុំសូមប្តេជ្ញាការពារសុខុមាលភាពរបស់សត្វទាំងអស់ដែលស្ថិតក្រោមការថែទាំរបស់ ហ្វ័រផ ដោយដឹងថា ហ្វ័រផ រួមបញ្ចូលនូវក្របខណ្ឌសុខុមាលភាពតែមួយ (One Welfare Framework) ដែលពិពណ៌នា

អំពីអន្តរទំនាក់ទំនងរវាងសុខុមាលភាពសត្វ សុខុមាលភាពមនុស្ស និងរូបរាងកាយ បរិស្ថាន និងសង្គមរបស់ពួកគេ ជាធាតុសំខាន់ដែលត្រូវយកមកពិចារណា ក្នុងការបរិយាយលម្អិត និងការអនុវត្តគោលនយោបាយ និងសកម្មភាពទាំងឡាយទាក់ទងនឹងទិដ្ឋភាពនីមួយៗ។

Safety and security

សុវត្ថិភាព និងសន្តិសុខ

3.3 In order to ensure my safety and security at work as well as the safety and security of others, including my colleagues, partners, visitors to our sanctuaries, and animals in our care, I will adhere to all applicable laws and regulations.

៣.៣ ដើម្បីធានាសុវត្ថិភាព និងសន្តិសុខរបស់ខ្ញុំនៅកន្លែង ធ្វើការ ក៏ដូចជាសុវត្ថិភាព និងសន្តិសុខរបស់អ្នកដទៃ រួមទាំងអ្នករួមការងារដៃគូរ ភ្ញៀវមកទស្សនកិច្ចទីជម្រក និងសត្វក្រោមការថែទាំរបស់យើង ខ្ញុំនឹងប្រកាន់ខ្ជាប់នូវច្បាប់ និងបទប្បញ្ញត្តិជាធរមានទាំងអស់។

3.4 I will follow all of FOUR PAWS internal standards which were drawn up to ensure the safety of all the above-mentioned groups.

៣.៤ ខ្ញុំនឹងអនុវត្តតាមស្តង់ដារផ្ទៃក្នុងទាំងអស់របស់ ហ្វ័រផ ដែលត្រូវបានបង្កើតឡើងដើម្បីធានាសុវត្ថិភាពនៃក្រុមទាំងអស់ដែលបានរៀបរាប់ខាងលើ។

4 GENERAL PRINCIPLES OF CONDUCT

៤ គោលការណ៍ប្រតិបត្តិទូទៅ

Protection of human rights

ការការពារសិទ្ធិមនុស្ស

4.1 I will respect and support the United Nations' Universal Declaration of Human Rights, and will only engage in activities which are in line with these rights.

៤.១ ខ្ញុំនឹងគោរព និងគាំទ្រសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ហើយនឹងចូលរួមតែក្នុងសកម្មភាពណាដែលស្របតាមសិទ្ធិទាំងនេះប៉ុណ្ណោះ។

4.2 I will be mindful of the rights of all people, especially children and other vulnerable groups.

៤.២ ខ្ញុំនឹងគិតគូរដល់សិទ្ធិទាំងអស់របស់មនុស្សជាតិ ជាពិសេសកុមារ និងក្រុមងាយរងគ្រោះផ្សេងទៀត។

4.3 I will follow the safeguarding measures and controls established by FOUR PAWS against modern slavery and I will work with contractors and partners who share FOUR PAWS commitment to fight modern slavery within their organisations and supply chains.

៤.៣ ខ្ញុំនឹងអនុវត្តតាមវិធានការការពារ និងវិធានគ្រប់គ្រងដែលបង្កើតឡើងដោយ ហ្វ័រផ ប្រឆាំងនឹងទាសភាពសម័យទំនើប ហើយខ្ញុំនឹងធ្វើការជាមួយបណ្តាអ្នកម៉ៅការ និងដៃគូដែលប្តេជ្ញាចិត្តរួមជាមួយ ហ្វ័រផ ដើម្បីប្រយុទ្ធប្រឆាំងនឹងទាសភាពសម័យទំនើបនៅក្នុងអង្គការ និងខ្សែសង្វាក់ផ្គត់ផ្គង់របស់ពួកគេ។

Compliance with legal provisions and internal standards

ការអនុលោមតាមបទប្បញ្ញត្តិច្បាប់ និងស្តង់ដារផ្ទៃក្នុង

4.4 I will ensure that I know all legal requirements which affect my professional duties.

៤.៤ ខ្ញុំនឹងធានាថា ខ្ញុំដឹងអំពីតម្រូវការគតិយុត្តិទាំងអស់ដែលមានឥទ្ធិពលលើភារកិច្ចវិជ្ជាជីវៈរបស់ពួកគេ។

4.5 I commit to acting in compliance with all legal provisions which affect my duties for FOUR PAWS. This includes, but is not limited to, all safety and health regulations as well as all applicable labour laws.

៤.៥ ខ្ញុំប្តេជ្ញាអនុលោមតាមបទប្បញ្ញត្តិគតិយុត្តិទាំងអស់ដែលមានឥទ្ធិពលលើភារកិច្ចរបស់ខ្ញុំ សម្រាប់ ហ្វ័រផ។ វារួមមានជាអាទិ៍ បទប្បញ្ញត្តិសុវត្ថិភាព និងសុខភាពទាំងអស់ ព្រមទាំងច្បាប់ស្តីពីការងារជាធរមានទាំងអស់។

4.6 I will comply with all internal standards developed by FOUR PAWS.

៤.៦ ខ្ញុំនឹងអនុលោមតាមស្តង់ដារផ្ទៃក្នុងទាំងអស់ដែលបង្កើតឡើងដោយ ហ្វ័រផ។

4.7 I will avoid any involvement in activities intended to circumvent legal requirements or internal standards.

៤.៧ ខ្ញុំនឹងជៀសវាងការជាប់ពាក់ព័ន្ធក្នុងសកម្មភាពដែលមានចេតនាគេចវេះពីតម្រូវការគតិយុត្តិ ឬស្តង់ដារផ្ទៃក្នុងនានា។

Diversity, equity and inclusion

ពិពិធភាព សមភាព និងបរិយាបន្ន

4.8 I will not discriminate against anyone, regardless of age, appearance, beliefs and principles, civil status, culture, disability, ethnicity, faith, gender, nationality, religion, sexual orientation, skin colour or other applicable legally protected characteristics.

៤.៨ ខ្ញុំនឹងមិនរើសអើងនរណាម្នាក់ឡើយ ពាក់ព័ន្ធនឹង អាយុ រូបរាង ជំនឿ និងគោលការណ៍ អត្រានុកូលដ្ឋាន វប្បធម៌ ពិការភាព ជាតិសាសន៍ ជំនឿ យេនឌ័រ សញ្ជាតិ សាសនា និន្នាការផ្លូវភេទ ពណ៌សម្បុរ ឬលក្ខណៈផ្សេងទៀតដែលត្រូវបានការការពារដោយច្បាប់។

4.9 I will treat everyone with empathy, respect, and understanding, and will not abuse, bully or harass others.

៤.៩ ខ្ញុំនឹងផ្តល់ដល់អ្នករាល់គ្នានូវការមេត្តា គោរព និងយោគយល់ហើយនឹងមិនបំពាន ធ្វើបាបគម្រាមកំហែង ឬបៀតបៀនអ្នកដទៃឡើយ។

4.10 I understand and support that FOUR PAWS strictly adheres to the principles of diversity, equity, and inclusion in all of its human resources activities, including the recruitment, hiring, training, assessment, and remuneration of all its employees, and I support these principles.

៤.១០ ខ្ញុំយល់ និងគាំទ្រចំពោះការណ៍ដែល ហ្វ័រផ ប្រកាន់ខ្ជាប់យ៉ាងម៉ឺងម៉ាត់នូវគោលការណ៍នៃពិពិធភាព សមភាព និងការដាក់បញ្ចូលក្នុងសកម្មភាពធនធានមនុស្សទាំងអស់របស់ខ្លួន រួមទាំងការជ្រើសរើស ការជួល ការបណ្តុះបណ្តាល ការវាយតម្លៃ និងការផ្តល់ប្រាក់បៀវត្សរបស់និយោជិតទាំងអស់ ហើយខ្ញុំគាំទ្រគោលការណ៍ទាំងនេះ។

Integrity

4.11 I commit to acting with integrity at all times, and take accountability for my decisions and actions.

4.12 I will adhere to FOUR PAWS anti-bribery, anti-fraud, and anti-corruption safeguarding standards, and will, through my own behaviour, contribute to a work environment which promotes the ethical behaviour of all colleagues at FOUR PAWS.

4.13 I am aware that conflicts of interest might occur when I or my family, my other relatives or my circle of friends and acquaintances receive undue advantage from my employment or provision of service at FOUR PAWS, or from the disclosure of or access to confidential information. I will identify potential conflicts of interests as early as possible and strive to avoid them.

4.14 I understand that there is an inherent conflict of interest in me becoming engaged in an intimate personal relationship with a colleague reporting to me or with my line manager. Should I enter into a relationship of this nature, I will disclose this fact to HR and to the relevant body within the organisation and seek to avoid this conflict.

4.15 I will not engage in any acts of fraud, or collude in any acts of fraud, including, but not limited to, acts of theft or misappropriation of funds.

សុចរិតភាព

៤.១១ ខ្ញុំសូមប្តេជ្ញាធ្វើសកម្មភាពប្រកបដោយសុចរិតភាពគ្រប់ពេលវេលា និងទទួលខុសត្រូវចំពោះការសម្រេចចិត្ត និងសកម្មភាពរបស់ខ្ញុំ។

៤.១២ ខ្ញុំនឹងប្រកាន់ខ្ជាប់នូវស្តង់ដារការងាររបស់ ហ្វ័រផ ស្តីពីការប្រឆាំងអំពើស៊ីសំណូក អំពើក្លែងបន្លំ និងអំពើពុករលួយ ហើយនឹងតាមរយៈឥរិយាបថរបស់ខ្ញុំផ្ទាល់ រួមចំណែកបង្កើតបរិយាកាសការងារមួយដែលលើកកម្ពស់នូវឥរិយាបថប្រកបដោយសីលធម៌នៃអ្នករួមការងារទាំងអស់នៅ ហ្វ័រផ។

៤.១៣ ខ្ញុំដឹងថាទំនាស់ផលប្រយោជន៍អាចកើតឡើងនៅពេលខ្ញុំ ឬគ្រួសារ សាច់ញាតិ ឬមិត្តភក្តិ និងអ្នកស្គាល់របស់ខ្ញុំទទួលបានអត្ថប្រយោជន៍ហួសហេតុពីការងារ ឬការផ្តល់សេវាកម្ម របស់ខ្ញុំនៅ ហ្វ័រផ ឬពីការបង្ហាញ ឬការចូលប្រើព័ត៌មានសម្ងាត់។ ខ្ញុំនឹងកំណត់រកទំនាស់ផលប្រយោជន៍ដែលអាចកើតមានឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ហើយព្យាយាមជៀសវាងទំនាស់ផលប្រយោជន៍នោះ។

៤.១៤ ខ្ញុំយល់ថាទំនាស់ផលប្រយោជន៍តែងមានជាប់មកជាមួយ នៅពេលដែលខ្ញុំមានទំនាក់ទំនងស្និទ្ធស្នាលផ្ទាល់ខ្លួនជាមួយអ្នករួមការងារដែលជាថ្នាក់ក្រោម ឬថ្នាក់លើរបស់ខ្ញុំ។ ប្រសិនបើខ្ញុំមានទំនាក់ទំនងបែបនេះ ខ្ញុំនឹងបង្ហាញរឿងនេះដល់ផ្នែកធនធានមនុស្ស និងផ្នែកពាក់ព័ន្ធនៅក្នុងអង្គការ ហើយព្យាយាមជៀសវាងទំនាស់នេះ។

៤.១៥ ខ្ញុំនឹងមិនចូលរួមក្នុងអំពើក្លែងបន្លំ ឬឃុបឃិតក្នុងអំពើក្លែងបន្លំណាមួយ រួមមានជាអាទិ៍ អំពើលួច ឬអំពើគៃបំបាត់ប្រាក់។

4.16 I will not accept or attempt to accept bribes of any kind for their own personal gain. I accept I must not profit personally from my employment by FOUR PAWS beyond my salary and other legal entitlements.

៤.១៦ ខ្ញុំនឹងមិនទទួលយក ឬប៉ុនប៉ងទទួលសំណូកគ្រប់ប្រភេទ ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ខ្ញុំឡើយ។ ខ្ញុំទទួលយកថាខ្ញុំមិនត្រូវរកប្រាក់ចំណេញដោយផ្ទាល់ពីការងាររបស់ខ្ញុំនៅ ហ្វ័រផ លើសពីប្រាក់បៀវត្សនិងសិទ្ធិស្របច្បាប់ផ្សេងទៀតរបស់ខ្ញុំឡើយ។

4.17 I will not engage in or tolerate any acts of corruption, including, but not limited to, the abuse of power for my own personal gain.

៤.១៧ ខ្ញុំនឹងមិនចូលរួម ឬមិនអត់ឱនឡើយ ចំពោះអំពើពុករលួយ រួមមានជាអាទិ៍ ការបំពានអំណាចដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ខ្ញុំ។

4.18 I will immediately report acts of fraud, bribery, or corruption or any suspicion of thereof to my line manager or other relevant function within the organisation appointed to receive such reports.

៤.១៨ ខ្ញុំនឹងរាយការណ៍ភ្លាមៗ នូវអំពើក្លែងបន្លំ អំពើស៊ីសំណូក ឬអំពើពុករលួយ ឬរាល់ការសង្ស័យអំពីអំពើទាំងនោះ ទៅកាន់ប្រធានផ្នែករបស់ខ្ញុំឬមុខងារពាក់ព័ន្ធផ្សេងទៀតនៅក្នុងស្ថាប័នដែលត្រូវបានតែងតាំងឱ្យទទួលរបាយការណ៍បែបនេះ។

Fundraising, financial management, lobbying, corporate engagement and partnerships

ការរៃអង្គាសមូលនិធិ ការគ្រប់គ្រងហិរញ្ញវត្ថុ ការបញ្ចុះបញ្ចូល (ការតស៊ូមតិ) ការចូលរួមពីសាជីវកម្ម និងភាពជាដៃគូ

4.19 I understand that FOUR PAWS conducts all fundraising activities in a manner which reflects the organisation's principles and its commitment to human and animal welfare, and I support and will contribute to this conduct.

៤.១៩ ខ្ញុំយល់ថា ហ្វ័រផ ធ្វើសកម្មភាពរៃអង្គាសប្រាក់ទាំងអស់ក្នុងលក្ខណៈមួយដែលឆ្លុះបញ្ចាំងពីគោលការណ៍របស់អង្គការ និងការប្តេជ្ញាចិត្តរបស់ខ្លួនចំពោះសុខុមាលភាពមនុស្ស និងសត្វ ហើយខ្ញុំគាំទ្រ ហើយនឹងរួមចំណែកដល់សកម្មភាពនេះ។

4.20 I understand that FOUR PAWS complies with all requirements put forth by local and national regulatory bodies in connection with its fundraising activities, and I support and will contribute to this conduct. I will behave accordingly in all tasks that involve fundraising activities.

៤.២០ ខ្ញុំយល់ថា ហ្វ័រផ គោរពតាមលក្ខខណ្ឌតម្រូវទាំងអស់ដែលដាក់ចេញដោយស្ថាប័ននិយតកម្មក្នុងស្រុក និងថ្នាក់ជាតិ ទាក់ទងនឹងសកម្មភាពរៃអង្គាសប្រាក់របស់ខ្លួន ហើយខ្ញុំគាំទ្រ ហើយនឹងរួមចំណែកដល់សកម្មភាពនេះ។ ខ្ញុំនឹងប្រព្រឹត្តឱ្យស្របតាមរាល់កិច្ចការដែលពាក់ព័ន្ធនឹងសកម្មភាពរៃអង្គាសប្រាក់នេះ។

4.21 I understand that FOUR PAWS is committed to using all funds and donations in a responsible manner in support of its charitable purposes, and I support this commitment.

៤.២១ ខ្ញុំយល់ថា ហ្វ័រផ ប្តេជ្ញាប្រើប្រាស់មូលនិធិ និងអំណោយទាំងអស់ក្នុងលក្ខណៈទទួលខុសត្រូវ ដើម្បីជាការគាំទ្រដល់គោលបំណងសប្បុរសធម៌របស់ខ្លួន ហើយខ្ញុំគាំទ្រការប្តេជ្ញាចិត្តនេះ។

4.22 I understand that FOUR PAWS is committed to following all procedures developed as part of the organisation’s financial control framework, including procedures for the management of cash, income and expenditure, and procedures for financial reporting, budgeting, and auditing. In disposing of my duties, I will follow all financial control procedures.

៤.២២ ខ្ញុំយល់ថា ហ្វ័រផ ប្តេជ្ញាអនុវត្តតាមនីតិវិធីទាំងអស់ដែលត្រូវបានបង្កើតឡើងជាផ្នែកនៃក្របខណ្ឌត្រួតពិនិត្យហិរញ្ញវត្ថុរបស់អង្គការ រួមទាំងនីតិវិធីសម្រាប់ការគ្រប់គ្រងសាច់ប្រាក់ ចំណូល និងចំណាយ និងនីតិវិធីសម្រាប់របាយការណ៍ហិរញ្ញវត្ថុ ថវិកា និងសវនកម្ម។ ក្នុងការបំពេញភារកិច្ចរបស់ខ្ញុំ ខ្ញុំនឹងអនុវត្តតាមនីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុទាំងអស់។

4.23 I understand that FOUR PAWS is a neutral organisation and shall not be identified or connected to any political party or movement. Hence, I will ensure this neutrality when engaging with politicians on behalf of FOUR PAWS and ensure that my personal views and this engagement does not damage the reputation of FOUR PAWS.

៤.២៣ ខ្ញុំយល់ថា ហ្វ័រផ គឺជាអង្គការអព្យាក្រឹត ហើយមិនត្រូវបានកំណត់អត្តសញ្ញាណ ឬជាប់ពាក់ព័ន្ធនឹងគណបក្សនយោបាយ ឬចលនាណាមួយឡើយ។ អាស្រ័យហេតុនេះ ខ្ញុំនឹងធានានូវអព្យាក្រឹតភាពនេះនៅពេលប្រាស្រ័យទាក់ទងជាមួយអ្នកនយោបាយក្នុងនាម ហ្វ័រផ ហើយធានាថា ទស្សនៈផ្ទាល់ខ្លួននិងការចូលរួមរបស់ខ្ញុំមិនធ្វើឱ្យប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់ ហ្វ័រផ ឡើយ។

4.24 I will only enter into a partnership or an agreement with other organisations, institutions, government bodies, or companies on behalf of FOUR PAWS if these collaborations do not damage the reputation of FOUR PAWS.

៤.២៤ ខ្ញុំនឹងចូលរួមក្នុងភាពជាដៃគូ ឬកិច្ចព្រមព្រៀងជាមួយអង្គការ ស្ថាប័ន អង្គភាពរដ្ឋាភិបាល ឬក្រុមហ៊ុនផ្សេងៗទៀតក្នុងនាម ហ្វ័រផ តែក្នុងករណីដែលកិច្ចសហការទាំងនោះ មិនធ្វើឱ្យប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់ ហ្វ័រផ ប៉ុណ្ណោះ។

4.25 I will only enter into a partnership or an agreement with other organisations, institutions, government bodies, or companies on behalf of FOUR PAWS if these collaborations contribute to the organisation’s strategic or operational goals.

៤.២៥ ខ្ញុំនឹងចូលរួមក្នុងភាពជាដៃគូ ឬកិច្ចព្រមព្រៀងជាមួយអង្គការ ស្ថាប័ន អង្គភាពរដ្ឋាភិបាល ឬក្រុមហ៊ុនផ្សេងៗទៀតក្នុងនាម ហ្វ័រផ តែក្នុងករណីដែលកិច្ចសហការទាំងនោះ រួមចំណែកដល់គោលដៅយុទ្ធសាស្ត្រ ឬប្រតិបត្តិការរបស់អង្គការប៉ុណ្ណោះ។

Sustainability

ចិរភាព

4.26 I commit to helping reduce the environmental impact of FOUR PAWS and will follow internal standards developed by FOUR PAWS to reduce the organisation's carbon footprint.

៤.២៦ ខ្ញុំសូមប្តេជ្ញាជួយកាត់បន្ថយផលប៉ះពាល់បរិស្ថានរបស់ ហ្វ័រផ ហើយនឹងអនុវត្តតាមស្តង់ដាផ្ទៃក្នុងដែលត្រូវបានបង្កើតឡើងដោយ ហ្វ័រផ ដើម្បីកាត់បន្ថយដានកាបូនរបស់អង្គការ។

4.27 I will use all of FOUR PAWS resources entrusted to me in a sustainable and transparent manner and will adhere to internal standards to improve resource efficiency.

៤.២៧ ខ្ញុំនឹងប្រើប្រាស់ធនធានទាំងអស់ដែល ហ្វ័រផ បានប្រគល់មកខ្ញុំប្រកបដោយចិរភាព និងតម្លាភាព ហើយនឹងប្រកាន់ខ្ជាប់នូវស្តង់ដាផ្ទៃក្នុង ដើម្បីបង្កើនសក្តិសិទ្ធភាពនៃធនធាន។

4.28 I will consider the consequences of my decisions and actions for the environment and take full responsibility for them.

៤.២៨ ខ្ញុំនឹងពិចារណាពីផលវិបាកនៃការសម្រេចចិត្ត និងសកម្មភាពរបស់ខ្ញុំចំពោះបរិស្ថាន ហើយទទួលខុសត្រូវទាំងស្រុងចំពោះផលវិបាកទាំងនោះ។

4.29 I will use my best efforts to identify and use suppliers who share FOUR PAWS principles and commitment to human and animal welfare, and the protection of the environment.

៤.២៩ ខ្ញុំនឹងខិតខំប្រឹងប្រែងឱ្យអស់ពីសមត្ថភាពរបស់ខ្ញុំ ដើម្បីកំណត់ និងប្រើប្រាស់អ្នកផ្គត់ផ្គង់ដែលមានគោលការណ៍ និងការប្តេជ្ញាចិត្តដូច ឬស្រដៀងគ្នាទៅនឹងគោលការណ៍របស់ ហ្វ័រផ ចំពោះសុខុមាលភាពមនុស្ស និងសត្វ និងការការពារបរិស្ថាន។

Management of information

ការគ្រប់គ្រងព័ត៌មាន

4.30 I will reflect the principles of FOUR PAWS in all my communications.

៤.៣០ ខ្ញុំនឹងបង្ហាញពីគោលការណ៍របស់ ហ្វ័រផ ក្នុងការប្រាស្រ័យទាក់ទងទាំងអស់របស់ខ្ញុំ។

4.31 I will hold in trust and confidence and not disclose without authorisation any information received during the course of my employment or provision of service (where applicable) at FOUR PAWS to third parties.

៤.៣១ ខ្ញុំនឹងរក្សាជាការសម្ងាត់ និងមិនលាតត្រដាងនូវរាល់ព័ត៌មាន ដែលខ្ញុំទទួលបានក្នុងអំឡុងពេលបំពេញការងារ ឬការផ្តល់សេវា (ប្រសិនបើពាក់ព័ន្ធ) របស់ខ្ញុំនៅ ហ្វ័រផ ដល់តតិយជនណាឡើយ បើគ្មានការអនុញ្ញាត។

4.32 I will keep confidential and safeguard any information entrusted to FOUR PAWS by third parties from unauthorised disclosure. I will disclose confidential information received from third parties only on a need-to-know basis, if specifically authorised by third parties, or if required by law.

៤.៣២ ខ្ញុំនឹងរក្សាជាការសម្ងាត់ និងការពាររាល់ព័ត៌មានដែលប្រគល់ឱ្យ ហ្វ័រផ ដោយតតិយជន មិនឱ្យមានការលាតត្រដាងដោយគ្មានការអនុញ្ញាតឡើយ។ ខ្ញុំនឹងលាតត្រដាងព័ត៌មានសម្ងាត់ដែលទទួលបានពីតតិយជន តែក្នុងករណីចាំបាច់ត្រូវដឹងប៉ុណ្ណោះ ប្រសិនបើមានការអនុញ្ញាតជាក់លាក់ពីតតិយជន ឬប្រសិនបើត្រូវបានតម្រូវដោយច្បាប់។

4.33 I will communicate truthfully, accurately and honestly with my colleagues, with third parties and, where appropriate, with the public, adhering to FOUR PAWS communication standards.

៤.៣៣ ខ្ញុំនឹងប្រាស្រ័យទាក់ទងប្រកបដោយសច្ចភាព សុក្រិតភាព និងសុចរិតភាពជាមួយអ្នករួមការងាររបស់ខ្ញុំ តតិយជន និងជាមួយសាធារណៈជន ក្នុងករណីពាក់ព័ន្ធ ដោយប្រកាន់ខ្ជាប់នូវស្តង់ដាទំនាក់ទំនងរបស់ ហ្វ័រផ។

4.34 I understand and accept that the external communications of FOUR PAWS will be handled by authorised colleagues, including the communication on FOUR PAWS official social media platforms.

៤.៣៤ ខ្ញុំយល់ និងទទួលស្គាល់ថា ការប្រាស្រ័យទាក់ទងខាងក្រៅរបស់ ហ្វ័រផ នឹងត្រូវបានចាត់ចែងឬគ្រប់គ្រងដោយសហការីដែលមានការអនុញ្ញាត រួមទាំងការប្រាស្រ័យទាក់ទងលើវេទិកាប្រព័ន្ធផ្សព្វផ្សាយសង្គមផ្លូវការរបស់ ហ្វ័រផ ផងដែរ។

4.35 I will adhere to FOUR PAWS social media standards in regard to my personal social media accounts and will ensure that others know that my personal account or statements do not represent FOUR PAWS. I will not state or imply that their personal opinions and social media content are authorised or endorsed by FOUR PAWS.

៤.៣៥ ខ្ញុំនឹងគោរពតាមស្តង់ដាប្រព័ន្ធផ្សព្វផ្សាយសង្គមរបស់ ហ្វ័រផ ទាក់ទងនឹងគណនីប្រព័ន្ធផ្សព្វផ្សាយសង្គមផ្ទាល់ខ្លួនរបស់ខ្ញុំហើយនឹងធានាថា អ្នកផ្សេងទៀតដឹងថា គណនីផ្ទាល់ខ្លួន ឬសេចក្តីថ្លែងការណ៍របស់ខ្ញុំមិនតំណាងឱ្យ ហ្វ័រផ ឡើយ។ ខ្ញុំនឹងមិនបញ្ជាក់ឬថ្លែងបញ្ឆិតបញ្ឆៀងថាទស្សនៈ និងមាតិកាលើប្រព័ន្ធផ្សព្វផ្សាយសង្គមរបស់ពួកគេត្រូវបានអនុញ្ញាត ឬគាំទ្រដោយ ហ្វ័រផ ឡើយ។

4.36 I will refrain from behaviour or conduct which I know or could reasonably be expected to know might reflect adversely on the reputation of FOUR PAWS.

៤.៣៦ ខ្ញុំនឹងចៀសវាងនូវឥរិយាបថ ឬទង្វើដែលខ្ញុំដឹង អាចត្រូវបានរំពឹងថានឹងដឹង ដោយមានមូលហេតុសមស្រប ដែលធ្វើឱ្យមានផលប៉ះពាល់អវិជ្ជមានដល់កេរ្តិ៍ឈ្មោះរបស់ ហ្វ័រផ។

Animal Welfare. Worldwide.

Data protection and responsible use of information technology resources

ការការពារទិន្នន័យ និងការប្រើប្រាស់ធនធានបច្ចេកវិទ្យាព័ត៌មានប្រកបដោយទំនួលខុសត្រូវ

4.37 I will protect personal data in accordance with all applicable laws. I will only collect, process, store, or use personal data for specific, explicit, and legitimate purposes, and to the extent to which it is necessary. I respect the comprehensive rights of natural persons whose data I collect, store, process, or use on behalf of FOUR PAWS.

៤.៣៧ ខ្ញុំនឹងការពារទិន្នន័យផ្ទាល់ខ្លួន (ទិន្នន័យអត្តសញ្ញាណបុគ្គល) ដោយអនុលោមតាមច្បាប់ជាធរមានទាំងអស់។ ខ្ញុំនឹងប្រមូល ដំណើរការ រក្សាទុក ឬប្រើប្រាស់ទិន្នន័យផ្ទាល់ខ្លួន សម្រាប់គោលបំណងជាក់លាក់ ច្បាស់លាស់ និងស្របច្បាប់ និងក្នុងកម្រិតដែលចាំបាច់ប៉ុណ្ណោះ។ ខ្ញុំគោរពសិទ្ធិទូលំទូលាយរបស់រូបវន្តបុគ្គលដែលទិន្នន័យរបស់ខ្លួន ត្រូវបានខ្ញុំប្រមូល រក្សាទុក ដំណើរការ ឬប្រើក្នុងនាមហ្វ័រផ។

4.38 I will follow all internal standards established by FOUR PAWS to ensure that the integrity of all of the organisation’s data and metadata is maintained, protected from misuse or loss, safeguarded and kept according to all applicable laws and regulations, and accessible only to colleagues who need access to it in their professional capacities.

៤.៣៨ ខ្ញុំនឹងអនុវត្តតាមស្តង់ដាផ្ទៃក្នុងទាំងអស់ដែលបង្កើតឡើងដោយ ហ្វ័រផ ដើម្បីធានាថា សុចរិតភាពនៃទិន្នន័យ និងទិន្នន័យមេតា (កម្រងទិន្នន័យ) ទាំងអស់របស់អង្គការ ត្រូវបានរក្សា ការពារពីការប្រើប្រាស់មិនត្រឹមត្រូវ ឬការបាត់បង់ ត្រូវបានការពារ និងរក្សាទុកដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមានទាំងអស់ ហើយអាចអាក់សេសសម្រាប់តែអ្នករួមការងារដែលត្រូវការអាក់សេសទិន្នន័យក្នុងសមត្ថភាពវិជ្ជាជីវៈរបស់គេប៉ុណ្ណោះ។

4.39 I will use information technology and tools provided by FOUR PAWS primarily for professional purposes and will only use FOUR PAWS information technology and tools for private purposes in accordance with internal standards. I understand that I must not use these devices and tools to download, store, or distribute any illegal content.

៤.៣៩ ខ្ញុំនឹងប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងឧបករណ៍ដែលផ្តល់ដោយ ហ្វ័រផ សម្រាប់គោលបំណងវិជ្ជាជីវៈជាចម្បង ហើយនឹងប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងឧបករណ៍របស់ ហ្វ័រផ សម្រាប់គោលបំណងឯកជន តែក្នុងករណីដែលអនុលោមតាមស្តង់ដាផ្ទៃក្នុងប៉ុណ្ណោះ។ ខ្ញុំយល់ថា ខ្ញុំមិនត្រូវប្រើប្រាស់គ្រឿងឧបករណ៍ (ហាដវែរ និងសុសវែរ) ទាំងនេះ ដើម្បីទាញយក រក្សាទុក ឬចែកចាយខ្លឹមសារ (មាតិកា) ខុសច្បាប់ណាមួយឡើយ។

5 CONSEQUENCES AND PENALTY OF BREACHING THE CODE OF CONDUCT

៥ ផលវិបាក និងការពិន័យចំពោះការបំពានក្រមប្រតិបត្តិ

5.1 I am aware of the weight of the choices I make and of my conduct. I understand that if I breach the Code of Conduct, it may constitute an infringement of applicable laws resulting in civil or criminal liability and may have an adverse effect on FOUR PAWS and FOUR PAWS employees.

៥.១ ខ្ញុំដឹងពីទម្ងន់ (សារៈសំខាន់) នៃការជ្រើសរើសដែលពួកគេបានធ្វើ និងការប្រព្រឹត្តរបស់ពួកគេ។ ខ្ញុំយល់ថា ប្រសិនបើខ្ញុំបំពានក្រមប្រតិបត្តិ នោះវាអាចជាការរំលោភលើច្បាប់ជាធរមាន ដែលបណ្តាលឱ្យមានការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ឬព្រហ្មទណ្ឌ ហើយអាចជះឥទ្ធិពលអវិជ្ជមានដល់ ហ្វ័រផ និងនិយោជិតរបស់ ហ្វ័រផ។

5.2 Therefore, I understand and accept that in case of my non-compliance with the provisions of this Code of Conduct, FOUR PAWS will take necessary response measures in accordance with applicable law for non-employees, and for FOUR PAWS employees, FOUR PAWs might need to take disciplinary actions, up to and including termination of my employment or, if necessary, reporting the incident to the relevant authorities.

៥.២ ហេតុដូច្នេះ ខ្ញុំយល់ និងទទួលស្គាល់ថា ក្នុងករណីពួកគេមិនគោរពតាមបទប្បញ្ញត្តិនៃក្រមប្រតិបត្តិនេះ ហ្វ័រផ នឹងចាត់វិធានការឆ្លើយតប ស្របតាមច្បាប់ជាធរមានសម្រាប់អ្នកមិនមែននិយោជិត ហើយសម្រាប់និយោជិត ហ្វ័រផ ប្រហែលជាត្រូវចាត់វិធានការវិន័យ រហូតដល់ និងរួមទាំងការបញ្ចប់ការងាររបស់ខ្ញុំឬរាយការណ៍ពីហេតុការណ៍នេះ ទៅអាជ្ញាធរពាក់ព័ន្ធ ក្នុងករណីចាំបាច់។

6 REPORTING OF MISCONDUCT

៦ ការរាយការណ៍អំពីកំហុស

6.1 If I becomes aware of any suspected breach of the Code of Conduct, whether deliberate or accidental, committed by myself or any of my colleague, I will report such incident without delay to my line manager (for FOUR PAWS employees) or other relevant person in charge within the organisation appointed to receive and handle such reports (for All the Target Group). The Compliance and Integrity line (https://four-paws.integrityline.app/) is always an option to report potential misconduct or legal breach.

៦.១ ប្រសិនបើខ្ញុំដឹងពីការសង្ស័យណាមួយថាមានការបំពានលើក្រមប្រតិបត្តិនេះ ទោះជាដោយចេតនា ឬអចេតនាក្តី ដែលប្រព្រឹត្តដោយខ្លួនខ្ញុំផ្ទាល់ ឬដោយក្រុមការងាររបស់ខ្ញុំណាមួយ ខ្ញុំនឹងរាយការណ៍ពីឧប្បត្តិហេតុនេះជាបន្ទាន់ ដល់អ្នកគ្រប់គ្រងផ្ទាល់របស់ខ្ញុំ (សម្រាប់និយោជិត ហ្វ័រផ) ឬបុគ្គលពាក់ព័ន្ធផ្សេងទៀតដែលទទួលបន្ទុកក្នុងអង្គការ ដែលត្រូវបានតែងតាំងឱ្យទទួល និងដោះស្រាយរបាយការណ៍ទាំងនោះ (សម្រាប់ក្រុមគោលដៅទាំងអស់)។ បណ្តាញសម្រាប់រាយការណ៍អំពីអនុលោមភាព និងសុចរិតភាព គឺ (https://four-paws.integrityline.app/) ដែលជាជម្រើសមួយសម្រាប់រាយការណ៍ពីការប្រព្រឹត្តមិនត្រឹមត្រូវ ឬការរំលោភច្បាប់។

6.2 Whenever I report a suspected breach of the Code of Conduct, I will only do so in good faith and in the knowledge that FOUR PAWS will ensure that I am not retaliated against and that I protected by the internal standards on reporting and responding mechanisms which provide instructions on how to confidentially report such suspected breaches.

៦.២ នៅពេលខ្ញុំរាយការណ៍អំពីការបំពានលើក្រមប្រតិបត្តិដែលបានសង្ស័យ ខ្ញុំនឹងធ្វើសេចក្តីរាយការណ៍នោះដោយសុទ្ធចិត្ត និងដោយដឹងយ៉ាងជាក់ច្បាស់ថា ហ្វ័រផ នឹងធានាថា ខ្ញុំមិនត្រូវបានគេសងសឹក និងថាខ្ញុំត្រូវបានការពារដោយស្តង់ដាផ្ទៃក្នុងស្តីពីយន្តការរាយការណ៍និងឆ្លើយតប ដែលមានចែងអំពីរបៀបរាយការណ៍ដោយសម្ងាត់ អំពីការបំពានដែលត្រូវបានសង្ស័យ។

6.3 I will, however, be mindful of the possible measures in accordance with applicable law or possible disciplinary action (as applicable) FOUR PAWS may take if I should choose to knowingly make false allegations. For clarity, the disciplinary action is only applicable I am an employee of FOUR PAWS.

៦.៣ ទោះយ៉ាងណាក៏ដោយ ខ្ញុំនឹងត្រូវគិតដល់វិធានដែលអនុលោមតាមច្បាប់ជរមាន ឬវិធានការវិន័យ (ប្រសិនបើអាចអនុវត្តបាន) ហ្វ័រផ អាចនឹងចាត់ធ្វើឡើងប្រសិនបើខ្ញុំធ្វើការចោទប្រកាន់មិនត្រឹមត្រូវដោយចេតនា។ ដើម្បីឲ្យច្បាស់ វិធានការវិន័យអនុវត្តបានចំពោះតែក្នុងករណី ដែលខ្ញុំជានិយោជិតរបស់ ហ្វ័រផ។

6.4 I will not attempt to prevent any of my colleagues or any other affected individual from reporting a suspected breach of the Code of Conduct.

៦.៤ ខ្ញុំនឹងមិនព្យាយាមរារាំងអ្នករួមការងាររបស់ខ្ញុំ ឬបុគ្គលដែលរងផលប៉ះពាល់ផ្សេងទៀត ក្នុងការរាយការណ៍អំពីការសង្ស័យរំលោភបំពានលើក្រមប្រតិបត្តិនេះឡើយ។

6.5 In case I am uncertain whether a particular behaviour is a breach of the Code of Conduct, I will seek advice from my line manager (applicable if I am one of FOUR PAWS employees) or other relevant person in charge within the organisation appointed to receive and handle such reports.

៦.៥ ក្នុងករណីដែលខ្ញុំមានភាពមិនច្បាស់លាស់ ថាតើឥរិយាបថណាមួយ គឺជាការលោភបំពានលើក្រមប្រតិបត្តិ នោះខ្ញុំនឹងស្វះស្វែងរកយោបល់ណែនាំពីអ្នកគ្រប់គ្រងផ្ទាល់របស់ខ្ញុំ (អនុវត្តបានចំពោះក្រុមគោលដៅ ដែលជានិយោជិតរបស់ ហ្វ័រផ) ឬបុគ្គលពាក់ព័ន្ធផ្សេងទៀតដែលទទួលបន្ទុកនៅក្នុងអង្គការ ដែលត្រូវបានតែងតាំងឱ្យទទួល និងដោះស្រាយរបាយការណ៍បែបនេះ។

6.6 Should my line manager be involved in the suspected breach of the Code of Conduct, I will report the incident to their superior or use the Compliance and Integrity line. Should other relevant person in charge within the organisation appointed to receive and handle such reports be involved in the suspected breach of the Code of Conduct, I will report the incident to their superior.

៦.៦ ប្រសិនបើអ្នកគ្រប់គ្រងផ្ទាល់របស់ខ្ញុំមានជាប់ពាក់ព័ន្ធនឹងការសង្ស័យថាបានបំពានលើក្រមប្រតិបត្តិនេះ ខ្ញុំនឹងរាយការណ៍ពីឧប្បត្តិហេតុនេះទៅថ្នាក់លើរបស់ពួកគេ ឬប្រើប្រាស់ប្រព័ន្ធសម្រាប់រាយការណ៍ពីអនុលោមភាព និងសុចរិតភាព (Compliance and Integrity line)។ ប្រសិនបើបុគ្គលដែលពាក់ព័ន្ធផ្សេងទៀត ដែលទទួលបន្ទុកនៅក្នុងអង្គការ ដែលត្រូវបានតែងតាំងឱ្យទទួល និងដោះស្រាយរបាយការណ៍បែបនេះ មានការពាក់ព័ន្ធនឹងការសង្ស័យថាបានបំពានលើក្រមប្រតិបត្តិនេះ ខ្ញុំនឹងរាយការណ៍ពីហេតុការណ៍នេះទៅថ្នាក់លើរបស់ពួកគេ។

ពាក្យគន្លឹះ

Key Terms

ការសូកប៉ាន់ Bribery	ការស្នើផ្តល់ ការសន្យា ឬការផ្តល់ឱ្យ ឬការទទួលបានអត្ថប្រយោជន៍ផ្នែកហិរញ្ញវត្ថុ ឬអត្ថប្រយោជន៍ផ្សេងទៀតដើម្បីធ្វើឱ្យមានការអនុវត្តកាតព្វកិច្ចមិនត្រឹមត្រូវដោយបុគ្គលម្នាក់ផ្សេងទៀត។ offering, promising, or giving or receiving a financial or other advantage to bring about an improper performance by another person
អព្យាក្រឹត Neutral	អង្គការ **ហ្វ័រផ** គឺជាអង្គការអព្យាក្រឹត ពីព្រោះ អង្គការនេះមិនចូលរួមក្នុងអរិភាព ហើយក៏មិនចូលខាងភាគីណាមួយក្នុងបញ្ហានយោបាយ ពូជសាសន៍ សាសនា ឬមនោគមវិជ្ជាឡើយ។ ហ្វ័រផ មានជំហរសកម្មផ្តោតលើបញ្ហាសុខុមាលភាពសត្វ។ ទោះយ៉ាងណាក៏ដោយ ដើម្បីធ្វើដូច្នេះបាន អង្គការត្រូវនៅជាអព្យាក្រឹត។ អព្យាក្រឹតភាព គឺជាវិធីសាស្រ្តមានប្រសិទ្ធភាពមួយដែលអាចឱ្យយើងទទួលបានការជឿទុកចិត្ត និងការចេញ-ចូលទៅកាន់សហគមន៍ដែលយើងធ្វើការជាមួយ។ FOUR PAWS is a neutral organisation in that it does not participate in hostilities and nor does it take sides in matters of political, racial, religious or ideological nature. FOUR PAWS takes an active stance on matters of animal welfare. In doing so, however, it remains neutral. Neutrality is a practical tool enabling us to gain trust of and access to the communities we work with.
ទាសភាពសម័យទំនើប Modern Slavery	ទោះបីជាទាសភាពសម័យទំនើប មិនត្រូវបានកំណត់អត្ថន័យនៅក្នុងច្បាប់ក៏ដោយ ពាក្យនេះត្រូវបានគេប្រើប្រាស់ជាពាក្យឆត្រ (ពាក្យទូទៅ) ដែលគ្របដណ្តប់លើការអនុវត្តផ្សេងៗដូចជា ពលកម្មដោយបង្ខំ ការបញ្ចាំខ្លួនដោះបំណុល អាពាហ៍ពិពាហ៍ដោយបង្ខំ និងការជួញដូរមនុស្ស។ ជាសំខាន់ ពាក្យនេះសំដៅទៅលើស្ថានភាពទាំងឡាយនៃការកេងប្រវ័ញ្ច ដែលបុគ្គលម្នាក់មិនអាចបដិសេធឬចាកចេញបាន ដោយសារតែការគំរាមកំហែង អំពើហិង្សា ការបង្ខិតបង្ខំ ការបោកបញ្ឆោត និង/ឬការរំលោភអំណាច។ https://www.un.org/en/observances/slavery-abolition-day “although modern slavery is not defined in law, it is used as an umbrella term covering practices such as forced labour, debt bondage, forced marriage, and human trafficking. Essentially, it refers to situations of exploitation that a person cannot refuse or leave because of threats, violence, coercion, deception, and/or abuse of power” https://www.un.org/en/observances/slavery-abolition-day
ទិន្នន័យអត្តសញ្ញាណបុគ្គល Personal Data	រាល់ព័ត៌មានដែលទាក់ទងនឹងរូបវន្តបុគ្គលដែលត្រូវបានកំណត់អត្តសញ្ញាណ ឬដែលអាចកំណត់អត្តសញ្ញាណបាន (‘ប្រធានទិន្នន័យ’)។ រូបវន្តបុគ្គលដែលអាចកំណត់អត្តសញ្ញាណបាន គឺជាបុគ្គលដែលអាចត្រូវបានកំណត់អត្តសញ្ញាណ ដោយផ្ទាល់ឬដោយប្រយោល ជាពិសេសដោយយោងទៅលើព័ត៌មានផ្សេងៗដូចជា៖ ឈ្មោះ លេខអត្តសញ្ញាណ ទិន្នន័យទីតាំង ព័ត៌មានអនឡាញ ឬទៅលើកត្តាមួយ ឬច្រើនជាក់លាក់ចំពោះអត្តសញ្ញាណរាងកាយ សរីរវិទ្យា ហ្សែន (សេនេទិច) ផ្លូវចិត្ត សេដ្ឋកិច្ច វប្បធម៌ ឬសង្គមរបស់បុគ្គលនោះ ”បទប្បញ្ញត្តិស្តីពីការការពារទិន្នន័យទូទៅ (GDPR) មាត្រា ៤។ “any information relating to an identified or identifiable natural person

Animal Welfare. Worldwide.

('data subject'); an identifiable natural person is one who can be identified, directly or indirectly, in particular by reference to an identifier such as a name, an identification number, location data, an online identifier or to one or more factors specific to the physical, physiological, genetic, mental, economic, cultural or social identity of that natural person" General Data Protection Regulation (GDPR) Article 4.

ឯកសារយោង
References

អង្គការសហប្រជាជាតិ (១០ ធ្នូ ១៩៤៨)៖ សេចក្តីសម្រេចរបស់មហាសន្និបាតលេខ ២១៧ ក – សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស។ URL៖ https://www.un.org/en/about-us/universal-declaration-of-human-rights
United Nations (10 December 1948): General Assembly resolution 217 A – Universal Declaration of Human Rights. URL: https://www.un.org/en/about-us/universal-declaration-of-human-rights

អង្គការពលកម្មអន្តរជាតិ (n.d) : ស្តង់ដារការងារអន្តរជាតិ។ បញ្ជីលិខិតុបករណ៍តាមប្រធានបទនិងស្ថានភាព។
International Labour Organization (n. d.): International Labour Standards. List of instruments by subject and status. URL: http://www.ilo.org/dyn/normlex/en/f?p=1000:12030:::NO :::